**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ
ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី
ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 23-Jan-2013, 14:27
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**
ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ**/Public
ចំណាត់ថ្នាក់ប្រភេទឯកសារ
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

**សារណារបស់លោក អៀង សារី ស្ដីពីច្បាប់ជាធរមាននៅក្នុងសំណុំរឿង ០០២/០១**

---

**ដាក់ដោយ:**

**ក្រុមមេធាវីការពារក្ដី អៀង សារី**
អាង ឧត្ដម
Michael G. KARNAVAS

**ចម្លងជូន:**

**ចៅក្រមអង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម **និល ណុន**
ចៅក្រម **យ៉ា ឧត្ដារ**
ចៅក្រម **យ៉ា សុខន**
ចៅក្រម Silvia CARTWRIGHT
ចៅក្រម Jean-Marc LAVERGNE
ចៅក្រមបម្រុង **ធូ មុន្នី**
ចៅក្រមបម្រុង Claudia FENZ

០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

**សហព្រះរាជអាជ្ញា:**

ជា លាង

Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

តាមរយៈសហមេធាវីការពារក្តីរបស់ខ្លួន (“ក្រុមមេធាវីការពារក្តី”) លោក អៀង សារី សូមលើកឡើងអំពីច្បាប់ជាធរមាន ទាក់ទងនឹងឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១ អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង អ.វ.ត.ក (“វិធាន”) និងការណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង[1]។ ដោយពិចារណាអំពីការកំណត់សារណាត្រឹមចំនួន ២០ ទំព័រដែលកំហិតដោយអង្គជំនុំជម្រះសាលាដំបូង[2] មេធាវីការពារក្តី សូមនិយាយយោងទៅលើសារណាពីមុនៗទាំងអស់ ដែលទាក់ទងច្បាប់ដែលត្រូវយកមកអនុវត្តនៅអ.វ.ត.ក[3]។ មេធាវីការពារក្តី រក្សាសិទ្ធិក្នុងការលើកឡើងសាជាថ្មីអំពី

---

[1] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើង “សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម ទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារ E163) និងពេលវេលាកំណត់នៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន” ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ ឯកសារ E163/5។

[2] *ដូចខាងលើ,* កថាខណ្ឌ ៥។

[3] ពាក្យស្នើសុំរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តន៍នៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដែលគេហៅថា *សហឧក្រិដ្ឋកម្មរួម* (JCE), ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៨ (“ពាក្យស្នើសុំប្រឆាំងនឹងការអនុវត្តន៍ JCE”), ឯកសារ D97; សេចក្តីសង្កេតបន្ថែមរបស់លោក អៀង សារី ស្តីពីការអនុវត្តន៍ទ្រឹស្តីសហឧក្រិដ្ឋកម្មរួម នៅ អ.វ.ត.ក, ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ (សេចក្តីសង្កេតបន្ថែមស្តីពី JCE”), ឯកសារ D97/7; ចម្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួររបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងបទល្មើសនៃការបាត់ខ្លួនមនុស្សដោយបង្ខំ និងសំណើសុំបន្ថែមចំនួនទំព័រដែលបានកំណត់, ថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០០៩ (“ចម្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងការបាត់ខ្លួនមនុស្សដោយបង្ខំ”), ឯកសារ D180/4; បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស អំពីការអនុវត្តន៍នៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដែលគេហៅថា សហឧក្រិដ្ឋកម្មរួម, ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១០ (“បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស. ស្តីពីសហឧក្រិដ្ឋកម្មរួម”), ឯកសារ D97/14/5; សំណើ អៀង សារី ប្រឆាំងនឹងការអនុវត្តន៍ការទទួលខុសត្រូវរបស់ថ្នាក់លើនៅ អ.វ.ត.ក, ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០ (“សំណើប្រឆាំងការអនុវត្តន៍ការទទួលខុសត្រូវរបស់ថ្នាក់លើ”), ឯកសារ D345/2; ជម្រើសមួយសំណើសុំរបស់លោក អៀង សារី ស្តីពីការអនុវត្តន៍ការទទួលខុសត្រូវរបស់ថ្នាក់លើនៅ អ.វ.ត.ក, ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១០ (“ជម្រើសមួយសំណើសុំស្តីពីការអនុវត្តន៍ការទទួលខុសត្រូវរបស់ថ្នាក់លើ”), ឯកសារ D345/3; សារណាតបរបស់លោក អៀង សារី ទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន ស្តីពីសហឧក្រិដ្ឋកម្មរួម, ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១០, ឯកសារ D97/14/14; បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការអនុវត្តន៍ទ្រឹស្តីនៃ ការទទួលខុសត្រូវរបស់ថ្នាក់លើ, ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១០ (“បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការអនុវត្តន៍ទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ”), ឯកសារ D345/5/1; សំណើរបស់ អៀង សារី ប្រឆាំងនឹងការអនុវត្តន៍ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅ អ.វ.ត.ក, ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១០, ឯកសារ D378 (“សំណើប្រឆាំងនឹងការអនុវត្តន៍ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ”); ចម្លើយតបរបស់លោក អៀង សារី ក្នុងការគាំទ្រដល់សារណាផ្ទាល់មាត់ក្នុងពេលសវនាការនៅចំពោះមុខ

---

អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងសារណាតបរបស់សហព្រះរាជអាជ្ញាទៅលើបណ្តឹងឧទ្ធរណ៍របស់ លោក អៀង សារី ស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើ, ថ្ងៃទី ២១ ឧសភា ឆ្នាំ ២០១០, ("ចម្លើយតបដើម្បីគាំទ្រសារណាផ្ទាល់មាត់") ឯកសារ D345/5/9; សំណើមួយទៀតរបស់លោក អៀង សារី ស្តីពីការកម្រិតភាពអាចអនុវត្តបាននៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅ អ.វ.ត.ក, ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១០ ("សំណើមួយទៀតស្តីពីការកម្រិតភាពអាចអនុវត្តបាននៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"), ឯកសារ D378/2; ចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦, ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១០ ("ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់ ក.ស.ព"), ឯកសារ D390/1/2/1.3; បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០, ឯកសារ D427/1/6 ("បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ"); សារណាឆ្លើយតបទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១០ ("សារណាឆ្លើយតបទៅនឹងចម្លើយតបរួមរបស់ ក.ស.ព ទៅនឹងបណ្តឹងឧទ្ធរណ៍"), ឯកសារ D427/1/23; ចម្លើយតបរបស់ អៀង សារី ចំពោះការឆ្លើយតបរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី *Advocats Sans Frontières* ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី, អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១០, ("ចម្លើយតបទៅនឹងការឆ្លើយតបរបស់មេធាវី *Advocats Sans Frontières* ទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ"), ឯកសារ D427/1/24; សារណាឆ្លើយតបទៅនឹងសេចក្តីសង្កេតរួមទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០១១ ("សារណាឆ្លើយទៅនឹងសេចក្តីសង្កេតរួមទៅនឹងបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ"), ឯកសារ D427/1/125; សេចក្តីសង្ខេបអញ្ញត្រកម្មតាមវិធាន ៨៩ របស់លោក អៀង សារី និងការជូនដំណឹងនៃការមិនគោរពតាមអនុស្សរណៈក្រៅផ្លូវការនានានាពេលអនាគត ដែលត្រូវបានចេញជំនួសឱ្យសេចក្តីសម្រេចមានសំអាងហេតុរបស់តុលាការ ដែលជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍, ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ("សេចក្តីសង្ខេបអញ្ញត្រកម្ម"), ឯកសារ E51/4; ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង ដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១១ ("ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ"), ឯកសារ E95/4; ចម្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ជាទម្រង់មួយទៀតនៃការទទួលខុសត្រូវ និងសំណើសុំឱ្យមានសវនាការផ្ទាល់មាត់ ដើម្បីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា, ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ("ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣"), ឯកសារ E100/2; សេចក្តីសង្កេតរបស់ អៀង សារី ទៅលើការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងចម្លើយតបនានារបស់មេធាវីការពារក្តី លើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យកំណត់បទចោទជាថ្មីឡើងវិញក្នុងដីកាដំណោះស្រាយ និងដកលក្ខខណ្ឌតម្រូវនៃទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១១, ឯកសារ E95/7; បណ្តឹងសាទុក្ខរបស់លោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើរបស់សហព្រះរាជអាជ្ញា សុំដកលក្ខខណ្ឌស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ ("បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ"), ឯកសារ E95/8/1/1។

ច្បាប់ជាធរមាន នៅក្នុងសារណាបញ្ចប់ការពិភាក្សាដេញដោល[4]។ សូមមើលឧបសម្ព័ន្ធ "ក" ស្តីពីច្បាប់ជាធរមាន ដែលមានភ្ជាប់មកជាមួយ។

**កំណត់សម្គាល់បឋមលើឧបសម្ព័ន្ធ "ក"**

1. ឧបសម្ព័ន្ធ "ក" ចែងអំពី៖ **ក.** ធាតុផ្សំយុត្តាធិការ (*ទូទៅ*) នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ **ខ.** ធាតុផ្សំនៃបទល្មើសដែលលើកឡើងនៅក្នុងសំណុំរឿង ០០២/០១ (អំពើមនុស្សឃាត ការសម្លាប់បំផុតពូជ ការធ្វើទុក្ខបុកម្នេញផ្អែកនយោបាយ និងពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងៗ ដោយរួមបញ្ចូលទាំងការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ)[5] និង **គ.** ធាតុផ្សំទម្រង់នៃការទទួលខុសត្រូវដែលលោក អៀង សារី ត្រូវបានចោទប្រកាន់។ ឧបសម្ព័ន្ធ "ក" លើកឡើងអំពីធាតុផ្សំនៃបទល្មើស និងទម្រង់នៃការទទួលខុសត្រូវតាមលំដាប់លំដោយ ដែលមានចែងនៅក្នុងមាត្រា៥ (ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ) និងមាត្រា ២៩ (ការទទួលខុសត្រូវជាបុគ្គល) នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក។ ហើយក៏មានការលើកឡើងអំពីការទទួលខុសត្រូវក្នុងទម្រង់សហឧក្រិដ្ឋកម្មរួម ទោះបីជាការទទួលខុសត្រូវបែបនេះ មិនមានចែងច្បាស់នៅក្នុងមាត្រា ២៩ ក៏ដោយ[6]។

2. លោក អៀង សារី ត្រូវបានសន្មតថាគ្មានទោស រហូតទាល់តែពិរុទ្ធភាពរបស់គាត់ត្រូវបានបង្ហាញ[7]។ ក.ស.ព មានបន្ទុកបង្ហាញភ័ស្តុតាង[8]។ អង្គជំនុំជម្រះសាលាដំបូងត្រូវតែបង្ហាញឱ្យឃើញអំពីពិរុទ្ធភាពរបស់លោក អៀង សារី ដោយគ្មានវិមតិសង្ស័យ មុនពេលដែលអង្គជំនុំជម្រះអាច

---

[4] *សូមមើល* អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "សេចក្តីបញ្ជាក់ស្តីពីការដាក់សារណាពាក់ព័ន្ធនឹងច្បាប់ជាធរមាន", ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១២, ឯកសារ E163/5/6។

[5] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង, ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១, ឯកសារ E124, កថាខណ្ឌ ៥។

[6] *សូមមើល* សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីសហឧក្រិដ្ឋកម្មរួម (JCE), ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០, ឯកសារ D47/14/15; សេចក្តីសម្រេចលើភាពអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម, ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១, ឯកសារ E100/6។

[7] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, អនុម័តនៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣ ("រដ្ឋធម្មនុញ្ញ"), មាត្រា ៣៨; កិច្ចព្រមព្រៀង, មាត្រា ១៣(១); ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ៣៥ថ្មី; វិធាន ២១(១)(ឃ)។

[8] វិធាន ៨៧(១)។

ផ្តន្ទាទោសលោក អៀង សារី អំពីបទល្មើសណាមួយ[9]។

3. ក្នុងនាមជាតុលាការកម្ពុជា អ.វ.ត.ក ត្រូវតែគោរពតាមច្បាប់កម្ពុជា[10] ដែលបានរួមបញ្ចូល គោលការណ៍នីត្យានុកូល (*គ្មានបទល្មើស បើគ្មានច្បាប់ចែង* (nullum crimen sine lege)) *គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* (in dubio pro reo) និង *គោលការណ៍នៃការអនុវត្តច្បាប់ដែលចែងអំពីទោសដែលស្រាល* (lex mitior)។ ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ រួមបញ្ចូលគោលការណ៍នីត្យានុកូលភាព ដោយបានចែងថា ជនជាប់ចោទមិនអាច ត្រូវបានផ្តន្ទាទោសចំពោះបទល្មើសដែលមិនមានចែងនៅក្នុងច្បាប់កម្ពុជា នៅពេលដែលប្រព្រឹត្ត បទល្មើសនោះទេ[11]។ ការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវតែអាចមើលឃើញជាមុន និងថា ច្បាប់

---

[9] *ដូចខាងលើ*។

[10] *សូមមើល* កិច្ចព្រមព្រៀង, មាត្រា ១២(១); វិធាន, បុព្វកថា។

[11] *សូមមើល* ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦, មាត្រា ៦៖ "ច្បាប់ព្រហ្មទណ្ឌគ្មានអានុភាពជាប្រតិសកម្មទេ គឺថា បទល្មើសណាបាន ប្រព្រឹត្តមុនបទប្បញ្ញត្តិរបស់ច្បាប់ បទល្មើសនោះមិនអាចត្រូវនិគ្រោះ ដោយទោសរបស់ច្បាប់ដែលទើបនឹងបញ្ញត្តិថ្មីនេះបានទេ។ ប៉ុន្តែ បើច្បាប់ថ្មីលុបចោលបទល្មើសណាមួយ ឬ សម្រាលទោសរបស់បទល្មើសណាមួយវិញ បទល្មើសដែលបានប្រព្រឹត្តមុន ច្បាប់ថ្មីនេះត្រូវបានរួចពីទោស ឬ ក៏ទោសនោះត្រូវបានស្រាលលតាមច្បាប់ថ្មីនេះដែរ កុំឲ្យតែបទល្មើសនោះបានទទួលការផ្តន្ទាជា ស្ថាពររួចអស់ទៅហើយ" (បកប្រែក្រៅផ្លូវការជាភាសាអង់គ្លេស)។ *សូមមើលផងដែរ* កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR"), មាត្រា ១៥(១), ដែលចែងជាផ្នែកថា៖ "គ្មានជនណាម្នាក់ ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ចំពោះអំពើ ឬការខកខានណាមួយ ដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិក្នុងខណៈ ពេលប្រព្រឹត្តនោះឡើយ"; សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស, U.N.G.A. Res. 217A(III), U.N. GAOR, 3rd Sess. មាត្រា ៧១, ឯកសារ អ.ស.ប លេខ A/810 (ឆ្នាំ ១៩៤៨), មាត្រា ១១(១)។ អនុលោមតាមរដ្ឋធម្មនុញ្ញ, កិច្ចព្រមព្រៀង និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, ការធានាដែលមាននៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវតែ គោរពតាម។ *សូមមើល* រដ្ឋធម្មនុញ្ញ, មាត្រា ៣១; ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ៣៣ថ្មី; កិច្ចព្រមព្រៀង, មាត្រា ១៣ (១)។ មេធាវីការពារក្តីជំទាស់ទៅនឹងសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គោលការណ៍នីត្យានុកូលភាពអាច ត្រូវបានបំពេញបាន ប្រសិនបើមានច្បាប់ចែងនៅក្នុងច្បាប់អន្តរជាតិ ឬនៅក្នុងគោលការណ៍ទូទៅរបស់ច្បាប់។ *សូមមើល សំណុំរឿង កាំងហ្គេកអ៊ាវ ហៅ ឌុច,* សំណុំរឿងលេខ ០០១/១៨ កក្កដា ២០០៧/អវតក/អជតក, សាលក្រមរបស់សាលាដំបូង, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ("សាលក្រមរបស់សាលដំបូងលើរឿងក្តី *ឌុច*"), កថាខណ្ឌ ២៨-៣៤។ និយមន័យនៃគោលការណ៍ នីត្យានុកូលភាពបែបនេះមានលក្ខណៈទូលំទូលាយ ដោយសារក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ បានតម្រូវថា ច្បាប់ត្រូវតែមានចែងក្នុង ច្បាប់ជាតិ នៅពេលបទល្មើសប្រព្រឹត្ត។ *សូមមើល* សេចក្តីសង្ខេបអញ្ញត្រកម្ម, កថាខណ្ឌ ២៤ ដោយយោងទៅដល់អញ្ញត្រកម្ម របស់លោក អៀង សារី ដែលថា អ.វ.ត.ក ពុំមានយុត្តាធិការដើម្បីអនុវត្តបទឧក្រិដ្ឋអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវ ប្រឆាំងនឹងគាត់ទេ។

ដែលចែងអំពីការទទួលខុសត្រូវនេះ ត្រូវតែអាចរកបានសម្រាប់ជនជាប់ចោទនៅពេលនោះ[12]។ គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* តម្រូវថា អង្គជំនុំជម្រះសាលាដំបូង ត្រូវតែដោះស្រាយការសង្ស័យណាមួយដើម្បីជាប្រយោជន៍ដល់លោក អៀង សារី[13]។ គោលការណ៍ *នៃការអនុវត្តច្បាប់ដែលចែងអំពីទោសដែលស្រាល* តម្រូវថា ច្បាប់មួយដែលចងភ្ជាប់កាតព្វកិច្ចអង្គជំនុំជម្រះសាលាដំបូង ត្រូវបានធ្វើវិសោធនកម្មទៅជាច្បាប់ ដែលផ្ដល់ផលប្រយោជន៍ច្រើនដល់ជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូង ត្រូវតែអនុវត្តច្បាប់ដែលផ្ដល់ផលប្រយោជន៍ច្រើននោះ[14]។

4. ច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលកំណត់ទោសចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មិនត្រូវបានយកមកអនុវត្តដោយផ្ទាល់នៅ អ.វ.ត.ក នោះទេ[15]។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើ

---

[12] *សូមមើល* សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ("សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ"), ឯកសារ D427/1/30, កថាខណ្ឌ ២២៩, ២៣៥-៣៦; សាលក្រមរបស់សាលដំបូងលើរឿងក្ដី *ឌុច*, កថាខណ្ឌ ២៨។

[13] មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញបានចែងពីគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ (in dubio pro reo)* និងបានតម្រូវថា ក្នុងករណីមានវិមតិសង្ស័យនឹងត្រូវដោះស្រាយជាប្រយោជន៍ដល់ជនជាប់ចោទ។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា គោលការណ៍នេះអនុវត្តចំពោះការបកស្រាយច្បាប់ ដែលជាវិធាននៃការបកស្រាយទៅតាមប្រព័ន្ធច្បាប់ស៊ីវិល។ សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្ដីពីសំណើសុំដោះលែងជាបន្ទាន់, ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១១, ឯកសារ E50/3/1/4, កថាខណ្ឌ ៣១៖ "ចំពោះគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* អាចអនុវត្តបានចំពោះស្ថានភាពលំបាកនៃអត្ថន័យច្បាប់ គោលការណ៍នេះត្រូវកម្រិតត្រឹមតែភាពមន្ទិលសង្ស័យដែលនៅតែមានក្រោយការបកស្រាយ។ ហេតុដូច្នេះ គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ត្រូវតែអនុវត្តយ៉ាងត្រឹមត្រូវចំពោះភាពមន្ទិលសង្ស័យអំពីខ្លឹមសារនៃបទដ្ឋានគតិយុត្តិ ដែលនៅតែមានក្រោយការអនុវត្តន៍នូវវិធាននៃការបកស្រាយតាមប្រព័ន្ធច្បាប់ស៊ីវិល ដោយធ្វើការពិចារណាទៅលើពាក្យពេចន៍នៃបទប្បញ្ញត្តិ ការដាក់បញ្ចូលក្នុងប្រព័ន្ធ រួមមានការជាប់ទាក់ទិននឹងគោលការណ៍សំខាន់ៗដែលជាមូលដ្ឋានគ្រឹះ និងគោលបំណងនៃគោលបំណងនៃគោលការណ៍នេះ"។

[14] ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦, មាត្រា ៦។ *សូមមើលផងដែរ* កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា ១៥(១); *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Deronjić*, សំណុំរឿងលេខ IT-02-61-A, សាលដីកាលើបណ្ដឹងឧទ្ធរណ៍, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៥, កថាខណ្ឌ ៩៧។

[15] *សូមមើល* ពាក្យស្នើសុំប្រឆាំងនឹងការអនុវត្តន៍ JCE, កថាខណ្ឌ ២៥-២៧; សំណើប្រឆាំងនឹងការអនុវត្តន៍ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, កថាខណ្ឌ ១៥-២១; បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ ១១១-១៤, ១២១-២៥; សារណាឆ្លើយទៅនឹងសេចក្ដីសង្កេតរួមទៅនឹងបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ ១០-១២; សេចក្ដីសង្ខេបអញ្ញត្រកម្ម, កថាខណ្ឌ ២៤។

អង្គជំនុំជម្រះសាលាដំបូង សម្រេចអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិ អង្គជំនុំជម្រះត្រូវបង្ហាញខ្លឹមសារដែលគួសបញ្ជាក់បានថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិ អាចយកមកប្រើប្រាស់បាន លុះត្រាតែអង្គជំនុំជម្រះអាចកំណត់ជារួមថា លក្ខខណ្ឌវិនិច្ឆ័យទាំងពីរត្រូវបានបំពេញ៖ **ក.** ការអនុវត្តរបស់រដ្ឋជាទូទៅ និងស៊ីសង្វាក់គ្នា និង **ខ.** *សច្ចធារណ៍ធម្មានុរូប* (*opinio juris*)[16]។ "ការអនុវត្តរបស់រដ្ឋ" គឺជា "កិច្ចព្រមព្រៀងតុណ្ហី" របស់រដ្ឋ តាមរយៈការអនុវត្ត និងការបង្ហាញឲ្យឃើញនូវអ្វីដែលរដ្ឋទាំងនោះជឿជាក់ថា ខ្លួនត្រូវបានចងភ្ជាប់កាតព្វកិច្ចផ្លូវច្បាប់ក្នុងចំណោមរដ្ឋទាំងនោះ[17]។ ទោះបីជាការអនុវត្តរបស់រដ្ឋ គួរតែ "ទូលំទូលាយ និងមានឯកភាពគ្នាជាក់ស្តែង ដើម្បីយកបទប្បញ្ញត្តិនោះមកប្រើប្រាស់"[18] ក៏ដោយ ក៏ការអនុវត្តរបស់រដ្ឋមិនចាំបាច់ "ត្រូវតែស្របដាច់ខាតទៅតាមវិធាននោះទេ"[19]។ *"គតិច្បាប់"* គឺជាការទទួលស្គាល់របស់រដ្ឋ ដែលការអនុវត្តជាក់ស្តែង

---

[16] ច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រូវបានបញ្ចូលនៅក្នុងមាត្រា ៣៨(១)(ខ) នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ ("ICJ") ជា "ទំនៀមទម្លាប់អន្តរជាតិ ជាភស្តុតាងនៃការអនុវត្តន៍ទូទៅដែលច្បាប់បានទទួលស្គាល់"។ *សូមមើល រឿងក្តី សកម្មភាពរបស់យោធា និងទាហានប៉ារ៉ា* (ប្រទេសនីការ៉ាហ្គ័រ តទល់នឹង ស.រ.អា), សំណុំរឿងលេខ 1986 I.C.J. 14, 98 (ថ្ងៃទី ២៧ ខែ មិថុនា) *("រឿងក្តី សកម្មភាពរបស់យោធា និងទាហានប៉ារ៉ា"), រឿងក្តី* Continental Shelf (ប្រទេសលីប៊ី តទល់នឹង ប្រទេសម៉ាល់តា), សំណុំរឿងលេខ 1985 I.C.J. 13, 29-30 (ថ្ងៃទី ៣ ខែ មិថុនា)៖ "ការពិតគឺថា គេត្រូវមើលជាបឋមទៅលើ ធាតុសម្ភារៈនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងទម្លាប់អនុវត្តន៍ជាក់ស្តែង និង *សច្ចធារណ៍ធម្មានុរូប* (*opinio juris*) របស់រដ្ឋ"។ ទស្សនាទាននៃទម្លាប់អនុវត្តន៍របស់រដ្ឋ និង *សច្ចធារណ៍ធម្មានុរូប* មានទំនាក់ទំនងយ៉ាងស្អិតរមួត និងអាចត្រួតលើគ្នាផង។ *សូមមើល* IAN BROWNLIE, **គោលការណ៍នៃច្បាប់អន្តរជាតិសាធារណៈ** 9 (បោះពុម្ពលើកទី ៦, OUP ឆ្នាំ ២០០៤) ("BROWNLIE"); **ការអះអាងសាជាថ្មីនៃច្បាប់ ស្តីពីទំនាក់ទំនងបរទេសរបស់សហរដ្ឋអាមេរិក (លើកទី៣)** § 102(2) (ឆ្នាំ ១៩៨៧) ដែលបានអនុម័តយកវិធីសាស្ត្រយ៉ាងវែងចំនួន ២ ដើម្បីបង្កើតជាទំនៀមទម្លាប់អន្តរជាតិ។

[17] *រឿងក្តី S.S. "Lotus"* (ប្រទេសបារាំង តទល់នឹង ប្រទេសទួរគី), សំណុំរឿងលេខ 1927 P.C.I.J. (ser. A) No. 10, ត្រង់ទំព័រ ១៨ (ភាសាអង់គ្លេស) (ថ្ងៃទី ៧ ខែ កញ្ញា) ដែលតុលាការព្រហ្មទណ្ឌអចិន្ត្រៃយ៍អន្តរជាតិ បានអះអាងថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិ គឺជាការបង្ហាញពីឆន្ទៈដោយសេរីរបស់រដ្ឋ។ *សូមមើល ផងដែរ* MALCOLM N. SHAW, **ច្បាប់អន្តរជាតិ** 84 (បោះពុម្ពលើកទី៦ CUP ឆ្នាំ ២០០៨) ("SHAW")៖ "រូបមន្តដែលថា "ទម្លាប់អនុវត្តន៍របស់រដ្ឋគ្របដណ្តប់ទៅលើសកម្មភាព ឬការថ្លែងរបស់រដ្ឋដែលអាចសន្និដ្ឋានពីទស្សនៈអំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិអាចត្រូវបាន" គឺជាការត្រឹមត្រូវ"។

[18] *រឿងក្តី North Sea Continental Shelf* (F.R.G. v. Den./F.R.G. v. Neth.) សំណុំរឿងលេខ 1969 I.C.J. 3, 43 (ថ្ងៃទី ២០ ខែ កុម្ភៈ) (*"រឿងក្តី North Sea Continental Shelf"*)។ *សូមមើលផងថែរ រឿងក្តី* Asylum (ប្រទេសកូឡុំប៊ី តទល់នឹង ប្រទេសប៉េរូ), សំណុំរឿងលេខ 1950 I.C.J. 266, 276 (ថ្ងៃទី ២០ ខែ វិច្ឆិកា) (*"រឿងក្តី Asylum"*); SHAW, ត្រង់ទំព័រ ៧៦-៧៨ (ភាសាអង់គ្លេស)។

[19] *រឿងក្តី សកម្មភាពរបស់យោធា និងទាហានប៉ារ៉ា,* ត្រង់ ទំព័រ ៩៨ (ភាសាអង់គ្លេស)។ ភាគីបណ្តឹងដែលលើកយកវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិមកសំអាងត្រូវបង្ហាញពីអត្ថិភាពនៃច្បាប់ទំនៀមទម្លាប់នោះ។ *រឿងក្តី Asylum,* ត្រង់ទំព័រ ២៧៦-

ត្រូវបាន "តម្រូវ"ដោយច្បាប់[20]។ ការផ្អែកលើកិច្ចព្រមព្រៀង និងសេចក្តីសម្រេចអន្តរជាតិ *តែប៉ុណ្ណឹង* គឺមិនគ្រប់គ្រាន់ដើម្បីបង្ហាញអំពី*គតិច្បាប់* និងការអនុវត្តរបស់រដ្ឋនោះទេ[21]។

5. ដើម្បីអនុវត្តតាមរដ្ឋធម្មនុញ្ញ និងគោលការណ៍*គ្មានបទល្មើស បើគ្មានច្បាប់ចែង* និង*គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* អង្គជំនុំជម្រះសាលាដំបូងត្រូវតែអនុវត្តនូវធាតុផ្សំនៃបទល្មើស និងទម្រង់នៃការទទួលខុសត្រូវ ដែលមានចែងនៅចន្លោះឆ្នាំ ១៩៧៥-១៩៧៩។

6. ឧបសម្ព័ន្ធ "ក" បានលើកឡើងចំណុចនានាដូចខាងក្រោម៖ **ក.** និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលតម្រូវឲ្យមានគោលនយោបាយរដ្ឋ ឬមានផែនការចាត់តាំង[22] និងចំណងទាក់ទង

---

៧៧ (ភាសាអង់គ្លេស)។ *សូមមើលផងដែរ* BROWNLIE, ត្រង់ទំព័រ ៧ (ភាសាអង់គ្លេស); DAVID HARRIS, **រឿងក្តី និងសម្ភារៈនានាស្តីពីច្បាប់អន្តរជាតិ** (បោះពុម្ពលើកទី ៦ OUP ឆ្នាំ ២០០៤), ជំពូក ២; HUGH THIRLWAY, *ប្រភពនៃច្បាប់អន្តរជាតិ* នៅក្នុង MALCOLM EVANS (ED.) **ច្បាប់អន្តរជាតិ** (បោះពុម្ពលើកទី ២ OUP ឆ្នាំ ២០០៦); J. Kammerhofer, *ភាពមិនច្បាស់លាស់នៅក្នុងប្រភពផ្លូវការនៃច្បាប់អន្តរជាតិ៖ ច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងបញ្ហាខ្លះៗរបស់វា* 15 EUR. J. INT'L L. 523 (ឆ្នាំ ២០០៤)។

[20] *រឿងក្តី North Sea Continental Shelf*, ត្រង់ទំព័រ ៤៤ (ភាសាអង់គ្លេស)៖ "ទង្វើទាំងនោះមិនត្រឹមតែដល់ទម្លាប់អនុវត្តន៍ដែលបានដោះស្រាយរួចហើយនោះទេ តែទង្វើទាំងនោះត្រូវតែជាទម្លាប់អនុវត្តន៍ ឬត្រូវបានអនុវត្តតាមវិធីបែបនេះ ជាភស្តុតាងនៃជំនឿដែលថា ទម្លាប់អនុវត្តនេះត្រូវធ្វើឡើងជាកាតព្វកិច្ចទៅតាមវិធាននៃច្បាប់ជាធរមានតម្រូវបែបនោះ ...។ ហេតុនេះ រដ្ឋដែលពាក់ព័ន្ធត្រូវយល់ថា ពួកគេកំពុងបង្កើតនូវអ្វីដែលជាកាតព្វកិច្ចគតិយុត្តិ ...។ ភាពញឹកញាប់ ឬលក្ខណៈជាទម្លាប់នៃទង្វើទាំងនេះមិនទាន់គ្រប់គ្រាន់ទេ"។ *សូមមើលផងដែរ* JL BRIERLY, **ច្បាប់របស់ប្រទេស៖ សេចក្តីផ្តើមចំពោះច្បាប់អន្តរជាតិនៃសន្តិភាព** 61 (បោះពុម្ពលើកទី ៦ Oxford University Press, ឆ្នាំ ១៩៦៣)។

[21] *សូមមើល* SHAW, ត្រង់ទំព័រ ៨២ (ភាសាអង់គ្លេស)៖ "វាជារបៀបដែលរដ្ឋប្រព្រឹត្តិនៅក្នុងទម្លាប់អនុវត្តន៍បង្កើតជាមូលដ្ឋាននៃច្បាប់ទំនៀមទម្លាប់ តែភស្តុតាងពីអ្វីដែលរដ្ឋធ្វើ គេអាចទទួលបានពីប្រភពនានាជាច្រើន"។ *សូមមើល ដូចខាងលើ,* ត្រង់ទំព័រ ៨៨ (ភាសាអង់គ្លេស)៖ "ទោះជាយ៉ាងណាក្តី គន្លឹះដែលសំខាន់គឺឥរិយាបថដែលរដ្ឋពាក់ព័ន្ធប្រកាន់យក ទោះបីក្នុងនាមជាភាគីនៃសន្ធិសញ្ញាជាក់លាក់ណាមួយ ឬជាអ្នកចូលរួមក្នុងការអនុម័តសេចក្តីសម្រេច អ.ស.ប"។ *សូមមើល ឧទាហរណ៍ នីត្យានុកូលភាពនៃការគម្រាមកំហែង ឬការប្រើប្រាស់អាវុធនុយក្លេអ៊ែរ,* យោបល់របស់ទីប្រឹក្សា, សំណុំរឿងលេខ 1966 I.C.J. 226, 253-56 (ថ្ងៃទី ៨ ខែ កក្កដា); *ផលវិបាកតាមផ្លូវច្បាប់សម្រាប់រដ្ឋនៅទ្វីបអាហ្វ្រិកខាងត្បូងដែលបន្តមានវត្តមាននៅប្រទេសណាមីប៊ី (ទ្វីបអាហ្វ្រិកពាយ័ព្យ) ថ្វីតែមានសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ២៧៦ ក៏ដោយ (ឆ្នាំ ១៩៧០), 276 (1970),* យោបល់របស់ទីប្រឹក្សា, សំណុំរឿងលេខ 1971 I.C.J. 16, 53-54 (ថ្ងៃទី ២១ ខែ មិថុនា) (ដែលបានពិភាក្សាពិភាពខុសគ្នារវាងសេចក្តីសម្រេចដែលចងកាតព្វកិច្ច និងមិនចងកាតព្វកិច្ច និងគុណភាពជាបទដ្ឋាននៃសេចក្តីសម្រេចទាំងនោះ)។

[22] *សូមមើល,* ឧបសម្ព័ន្ធ ក, កថាខណ្ឌ ៧-១០។

នឹងជម្លោះប្រដាប់អាវុធ[23] **ខ.** ការជម្លៀសដោយបង្ខំ[24] ឬការបាត់ខ្លួនដោយបង្ខំ[25] មិនត្រូវបានទទួលស្គាល់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេ។ **គ.** អង្គជំនុំជម្រះសាលាដំបូង មិនមានយុត្តាធិការលើ "អំពើអមនុស្សធម៌ផ្សេងៗ"[26] នោះទេ។ **ឃ.** សហឧក្រិដ្ឋកម្មរួម មិនបានកើតមានក្នុងទម្រង់ជាការទទួលខុសត្រូវនោះទេ[27]។ **ង.** ការទទួលខុសត្រូវរបស់ថ្នាក់លើ មិនបានកើតមានក្នុងទម្រង់ជាការទទួលខុសត្រូវនោះទេ[28]។ និង **ច.** ប្រសិនបើការទទួលខុសត្រូវរបស់ថ្នាក់លើកើតមាននៅក្នុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ករណីនេះត្រូវតែអនុវត្តចំពោះជម្លោះប្រដាប់អាវុធអន្តរជាតិប៉ុណ្ណោះ[29]។ ករណីនេះមិនអនុវត្តចំពោះថ្នាក់លើខាងផ្នែកស៊ីវិលទេ[30] និងតម្រូវឲ្យមានភស្តុតាងហេតុនិងផល[31]។ ថ្នាក់លើខាងផ្នែកស៊ីវិលអាចទទួលខុសត្រូវ ប្រសិនបើពួកគាត់មានតួនាទីជាមុន ដើម្បីប្រព្រឹត្ត[32] និងមិនអនុវត្តចំពោះឧក្រិដ្ឋកម្មដោយមានចេតនាជាក់លាក់ទេ[33]។

សូមអង្គជំនុំជម្រះសាលាដំបូង មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

សហមេធាវីការពារក្តីលោក អៀង សារី

**អាង ឧត្តម** **Michael G. KARNAVAS**

បានចុះហត្ថលេខានៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣

---

[23] *សូមមើល ដូចខាងលើ,* កថាខណ្ឌ ១១-១២។
[24] *សូមមើល ដូចខាងលើ,* កថាខណ្ឌ ១៨។
[25] *សូមមើល ដូចខាងលើ,* កថាខណ្ឌ ២១។
[26] *សូមមើល ដូចខាងលើ,* កថាខណ្ឌ ២៣-២៤។
[27] *សូមមើល ដូចខាងលើ,* កថាខណ្ឌ ៣១-៣៣។
[28] *សូមមើល ដូចខាងលើ,* កថាខណ្ឌ ៣៦-៣៩។
[29] *សូមមើល ដូចខាងលើ,* កថាខណ្ឌ ៤០។
[30] *សូមមើល ដូចខាងលើ,* កថាខណ្ឌ ៤០។
[31] *សូមមើល ដូចខាងលើ,* កថាខណ្ឌ ៤១។
[32] *សូមមើល ដូចខាងលើ*។
[33] *សូមមើល ដូចខាងលើ*។